# AGREEMENT
## ON THE ESTABLISHMENT OF SISTER –CITY RELATIONSHIP BETWEEN THE PHNOM PENH CAPITAL CITY OF THE KINGDOM OF CAMBODIA AND THE BANGKOK METROPOLITAN ADMINISTRATION OF THE KINGDOM OF THAILAND

The Bangkok Metropolitan Administration of the Kingdom of Thailand and the Phnom Penh Capital City of the Kingdom of Cambodia (hereinafter referred to as "The Parties") have agreed to establish the Sister-City Relationship under the positive law of the Parties for the following purposes:

1. To promote and expand the effective and mutually beneficial cooperation between the people of Phnom Penh and the people of Bangkok,
2. To promote international goodwill and understanding between the two cities and their respective nation by exchanging of views and information in a wide variety of economic, social, cultural, education, environment, professional, technical and other projects,
3. To foster and encourage scientific, economic, literary and education activities-human resource training between the two cities; and
4. To promote and facilitate investors of both cities to meet, discuss and exchange investment experience in Phnom Penh and Bangkok in compliance with their respective laws and regulations, equality and mutual interests.

This Agreement shall come into force from the date of signature.

Done in Phnom Penh on January 04, 2012 in six original copies in the Cambodian, Thai and English languages, all three texts being of equal authenticity. In case of divergence, the English text shall prevail.

| | |
|---|---|
| **KEP CHUK Tema** | **M.R. Sukhumbhand PARIBATRA** |
| Governor of Phnom Penh Capital City | Governor of Bangkok Metropolitan City |
| Kingdom of Cambodia | Kingdom of Thailand |

# កិច្ចព្រមព្រៀង
# ស្តីពីការបង្កើតទំនាក់ទំនងសម្ព័ន្ធមេត្រីភាព
# រវាង
# រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា
# និងរាជធានីបាងកក នៃព្រះរាជាណាចក្រថៃ

**រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា** និង **រាជធានីបាងកក នៃព្រះរាជាណាចក្រថៃ** (ជាភាគីនៃកិច្ចព្រមព្រៀងនេះ) បានព្រមព្រៀងបង្កើតនូវទំនាក់ទំនងសម្ព័ន្ធមេត្រីភាព ដែលស្ថិតនៅក្រោមច្បាប់ជាធរមាន នៃប្រទេសរបស់ភាគីទាំងពីរ ក្នុងគោលបំណងដូចខាងក្រោម:

១- ដើម្បីលើកកម្ពស់ និងពង្រីកនូវកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែមានប្រសិទ្ធិភាពរវាងប្រជាពលរដ្ឋនៃរាជធានីភ្នំពេញ និងប្រជាពលរដ្ឋនៃរាជធានីបាងកក ។

២- ដើម្បីលើកកម្ពស់នូវការយោគយល់គ្នា និងមេត្រីភាពរវាងប្រជាជាតិ និងទីក្រុងទាំងពីរតាមរយៈការផ្លាស់ប្តូរនូវទស្សនៈវិស័យ និងព័ត៌មាននៃគម្រោងទាក់ទងនឹងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ការអប់រំ បរិស្ថាន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសនានា។

៣- ជំរុញ និងលើកទឹកចិត្តឱ្យមាននូវសកម្មភាពនានាដែលទាក់ទងនឹងវិទ្យាសាស្ត្រ សេដ្ឋកិច្ច អក្សរសាស្ត្រ ការអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្សរវាងទីក្រុងទាំងពីរ។

៤- ជំរុញ និងបង្កលក្ខណៈងាយស្រួលដល់បណ្តាអាជីវកររបស់ទីក្រុងទាំងពីរ បានជួបពិភាក្សាផ្លាស់ប្តូរបទពិសោធន៍លើការបណ្តាក់ទុនរកស៊ីនៅទីក្រុងភ្នំពេញ និងទីក្រុងបាងកក ដោយគោរពទៅតាមច្បាប់នៃប្រទេសនីមួយៗតាមគោលការណ៍ស្មើភាព និងមានផលប្រយោជន៍ទាំងសងខាង ។

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣ ជា ០៦ (ប្រាំមួយ)ច្បាប់ ។ ច្បាប់ដើមជាភាសាខ្មែរ០២ច្បាប់ ភាសាថៃ០២ ច្បាប់ និងភាសាអង់គ្លេស ០២ ច្បាប់។ កិច្ចព្រមព្រៀងធ្វើជាបីភាសាមានតម្លៃផ្លូវច្បាប់ស្មើៗគ្នា ។ ក្នុងករណីមានភាពខ្វែងគំនិតគ្នា កិច្ចព្រមព្រៀងដែលធ្វើជាភាសាអង់គ្លេសត្រូវបានយកធ្វើជាគោលក្នុងការបកស្រាយ ។

| | |
|---|---|
| **កែប ជុតិមា** | **សុខុមផាន់ បារិបាត់** |
| **អភិបាលរាជធានីភ្នំពេញ** | **អភិបាលរាជធានីបាងកក** |
| **ព្រះរាជាណាចក្រកម្ពុជា** | **ព្រះរាជាណាចក្រថៃ** |